# មាតិកា

ទិ្វសស្នាដៃ---------- ii
មាតិកា---------- iii
សេចក្តីថ្លែងអំណរគុណ---------- viii
សេចក្តីសង្ខេបជាខេមរភាសា---------- xi
សេចក្តីសង្ខេបជាភាសាអង់គ្លេស---------- xvii
ពាក្យប្រើជាអក្សរកាត់---------- xxii
បញ្ជីតារាង---------- xxv
បញ្ជីរូបភាព---------- xxx

១. លំនាំដើម---------- ១
២. សេចក្តីផ្តើម---------- ២
២.១. ចំណោទបញ្ហា---------- ៤
២.២. សម្មតិកម្ម---------- ៥
២.៣. គោលបំណងនៃការស្រាវជ្រាវ---------- ៥
២.៤. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ---------- ៦
២.៥. ទិសដៅ និងទំហំនៃការស្រាវជ្រាវ---------- ៧
២.៦. ការស្រាវជ្រាវស្ថានីយតាមរយៈរូបថតពីលើអាកាស----------៩
២.៧. ការផ្តោមផែនទី និងភូមិសាស្ត្រទីតាំងស្រាវជ្រាវ---------- ១១

## ជំពូកទី ១

## ប្រវត្តិនៃការសិក្សាបុរាណវិទ្យានៅប្រទេសកម្ពុជា

១.១. ប្រវត្តិនៃការសិក្សាស្រាវជ្រាវ---------- ១៣
១.១.១. ស្ថានីយសំរោងសែន---------- ១៦
១.១.២. ស្ថានីយអន្លង់ផ្តៅ---------- ២០
១.១.៣. ស្ថានីយម្លូព្រៃ---------- ២០
១.១.៤. ស្ថានីយតំបន់អង្គរ---------- ២១
១.១.៥. សំណង់ដីរាងមូល---------- ២១

១.១.៦. ស្ថានីយយុគថ្មបំបែក---------------------------------------------------------------- ២៧
១.១.៧. ស្ថានីយល្អាងស្ពាន---------------------------------------------------------------- ៣១
១.១.៨. ស្ថានីយភ្នំល្អាង ខេត្តកំពត---------------------------------------------------------- ៣៥
១.១.៩. ការចាប់ផ្តើមស្រាវជ្រាវវិស័យបុរេប្រវត្តិសាស្ត្រខ្មែរសម័យក្រោយសង្គ្រាម----- ៣៨
១.១.១០. ស្ថានីយអង្គរបុរី---------------------------------------------------------------- ៣៨
១.១.១១. ការសិក្សាលើស្ថានីយបន្ទាយគូ----------------------------------------------- ៤១
១.១.១២. ការសិក្សាអំពីរូងភ្នំ---------------------------------------------------------- ៤២
១.១.១៣. ស្ថានីយភូមិស្នាយ ខេត្តបន្ទាយមានជ័យ-------------------------------------- ៤៣
១.១.១៤. ស្ថានីយពាមជាំង---------------------------------------------------------------- ៥២
១.១.១៥. ស្ថានីយស្លូង---------------------------------------------------------------------- ៥៦
១.១.១៦. ស្ថានីយចំការអណ្តូង-------------------------------------------------------------- ៥៩

## ជំពូកទី ២

## ស្ថានភាពទូទៅស្ថានីយបន្ទាយគូ

២.១.ស្ថានីយបន្ទាយគូ------------------------------------------------------------------------- ៦៣
២.១.១. តំណាលរឿងព្រេងទាក់ទងនឹងស្ថានីយ------------------------------------------ ៦៤
២.១.២. ប្រវត្តិនៃការស្រាវជ្រាវស្ថានីយបន្ទាយគូនៃអរិយធម៌មេមត់-------------------- ៦៥
២.១.៣. ការស្រាវជ្រាវក្នុងអត្ថបទព្រឹត្តិប័ត្របារាំងចុងបូព៌ាឆ្នាំ១៩៣០------------------ ៦៦
២.១.៤. ការស្រាវជ្រាវរបស់លោកល្វី មាល់ឡឺរ៉េ ឆ្នាំ១៩៥៩--------------------------- ៦៧
២.១.៥. ការស្រាវជ្រាវរបស់លោក ហ្វ្រូសលីយេ ឆ្នាំ១៩៦២--------------------------- ៧៧
២.១.៦.ការស្រាវជ្រាវរបស់វិទ្យាស្ថានវិទ្យាសាស្ត្រសង្គមក្រុងហូជីមិញប្រទេសវៀតណាម----៨២
២.១.៧. ការស្រាវជ្រាវរបស់លោក ភូ ចូ និងលោក ជេង ស៊ីថា ឆ្នាំ១៩៩៦----------- ៨៤
២.១.៨. ការស្រាវជ្រាវរបស់លោក ម៉ៃយើល ដេហ្គា ឆ្នាំ១៩៩៦------------------------ ៨៦
២.១.៩.ការស្រាវជ្រាវរបស់សាកលវិទ្យាល័យទូប៊ីញកិននិងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ-------៨៩
២.១.១០. ការស្រាវជ្រាវរបស់មជ្ឈមណ្ឌលបុរាណវិទ្យាមេមត់--------------------------- ៩១
២.២. ស្ថានីយបន្ទាយគូនៅក្នុងប្រទេសកម្ពុជា----------------------------------------------- ៩៣
២.២.១. លក្ខណៈទូទៅនៃស្ថានីយ---------------------------------------------------------- ៩៣
២.២.២. ដង់ស៊ីតេនៃការបែងចែកទីតាំងស្ថានីយនៅកម្ពុជា-------------------------- ១២៣
២.៣. បុរេប្រវត្តិសាស្ត្រនៃប្រទេសវៀតណាម------------------------------------------------ ១២៣

៣.៥. ប្រភេទឧបករណ៍ថ្មនៅស្ថានីយបន្ទាយគូ------------------------------------------ ២០៥
៣.៥.១. បំណែកថ្ម និងការផលិត------------------------------------------ ២០៧
៣.៥.២. ពូថៅ និងពន្លាក------------------------------------------ ២១៦
៣.៥.៣. ថ្មសំលៀង------------------------------------------ ២៣៩
៣.៥.៤. កងដៃ------------------------------------------ ២៤៩
៣.៥.៥. ថ្មបំបែក------------------------------------------ ២៥៤
៣.៥.៦. ដុំពណ៌------------------------------------------ ២៥៦
៣.៥.៧. ថ្មសំឡេង------------------------------------------ ២៥៧
៣.៥.៨. វត្ថុធាតុដើមសំរាប់ផលិតឧបករណ៍ថ្ម "ថ្មបាសាល់"------------------------------------------ ២៦១
៣.៦. វត្ថុធ្វើពីដីដុត------------------------------------------ ២៦៧
៣.៦.១. ប្រភេទកុលាលភាជន៍ស្ថានីយបន្ទាយគូ------------------------------------------ ២៦៧
៣.៦.២. ស្ថិតិកុលាលភាជន៍ស្ថានីយបន្ទាយគូ------------------------------------------ ២៦៨
៣.៦.៣.បំណែកកុលាលភាជន៍------------------------------------------ ២៧៤
៣.៦.៤. ពណ៌កុលាលភាជន៍------------------------------------------ ២៨២
៣.៦.៥. វត្ថុធាតុផ្សំ កុលាលភាជន៍------------------------------------------ ២៨៨
៣.៦.៦. ផ្ទៃសម្រេច និងទម្រង់ កុលាលភាជន៍------------------------------------------ ២៩១
៣.៦.៧.ក្បាច់លំអ កុលាលភាជន៍------------------------------------------ ២៩៤
៣.៦.៨. វត្ថុធ្វើពីដីដុតផ្សេងទៀត------------------------------------------ ៣០០
៣.៦.៩. ក្លីង------------------------------------------ ៣០១
៣.៦.១០. ខ្នារ------------------------------------------ ៣០២
៣.៦.១១. កុលាលភាជន៍ស្ថានីយបន្ទាយគូនៅវៀតណាម------------------------------------------៣០៣
៣.៧. ការប្រៀបធៀប ស្ថានីយបន្ទាយគូ ជាមួយស្ថានីយបុរេប្រវត្តិសាស្ត្រផ្សេង--------៣០៩

## ជំពូកទី ៤

## លទ្ធផលនៃការស្រាវជ្រាវ

៤.១. ដង់ស៊ីតេស្ថានីយបន្ទាយគូ------------------------------------------ ៣១៤
៤.២ ទីតាំងស្ថានីយបន្ទាយគូ------------------------------------------ ៣១៦
៤.៣ លក្ខណៈទូទៅស្ថានីយបន្ទាយគូ------------------------------------------ ៣១៨
៤.៤ របកគំហើញក្នុងវណ្តៅបុរាណវិទ្យា------------------------------------------ ៣២២

៣.៥. ប្រភេទឧបករណ៍ថ្មនៅស្ថានីយបន្ទាយគូ-------------------- ២០៥
៣.៥.១. បំណែកថ្ម និងការផលិត-------------------- ២០៧
៣.៥.២. ពូថៅ និងពន្លាក-------------------- ២១៦
៣.៥.៣. ថ្មសំលៀង-------------------- ២៣៩
៣.៥.៤. កងដៃ-------------------- ២៤៩
៣.៥.៥. ថ្មបំបែក-------------------- ២៥៤
៣.៥.៦. ដុំពណ៌-------------------- ២៥៦
៣.៥.៧. ថ្មសំឡេង-------------------- ២៥៧
៣.៥.៨. រូបធាតុដើមសំរាប់ផលិតឧបករណ៍ថ្ម "ថ្មបាសាល់"-------------------- ២៦១
៣.៦. វត្ថុធ្វើពីដីដុត-------------------- ២៦៧
៣.៦.១. ប្រភេទកុលាលភាជន៍ស្ថានីយបន្ទាយគូ-------------------- ២៦៧
៣.៦.២. ស្ថិតិកុលាលភាជន៍ស្ថានីយបន្ទាយគូ-------------------- ២៦៨
៣.៦.៣.បំណែកកុលាលភាជន៍-------------------- ២៧៤
៣.៦.៤. ពណ៌កុលាលភាជន៍-------------------- ២៨២
៣.៦.៥. វត្ថុធាតុផ្សំ កុលាលភាជន៍-------------------- ២៨៨
៣.៦.៦. ផ្ទៃសម្រេច និងទម្រង់ កុលាលភាជន៍-------------------- ២៩១
៣.៦.៧.ក្បាច់លំអ កុលាលភាជន៍-------------------- ២៩៤
៣.៦.៨. វត្ថុធ្វើពីដីដុតផ្សេងទៀត-------------------- ៣០០
៣.៦.៩. ភ្លឹង-------------------- ៣០១
៣.៦.១០. ខ្នារ-------------------- ៣០២
៣.៦.១១. កុលាលភាជន៍ស្ថានីយបន្ទាយគូនៅវៀតណាម-------------------- ៣០៣
៣.៧. ការប្រៀបធៀប ស្ថានីយបន្ទាយគូ ជាមួយស្ថានីយបុរេប្រវត្តិសាស្ត្រផ្សេង-------- ៣០៩

## ជំពូកទី ៤

## លទ្ធផលនៃការស្រាវជ្រាវ

៤.១. ដង់ស៊ីតេស្ថានីយបន្ទាយគូ-------------------- ៣១៤
៤.២ ទីតាំងស្ថានីយបន្ទាយគូ-------------------- ៣១៦
៤.៣ លក្ខណៈទូទៅស្ថានីយបន្ទាយគូ-------------------- ៣១៨
៤.៤ របកគំហើញក្នុងរណ្ដៅបុរាណវិទ្យា-------------------- ៣២២

- វត្ថុផលិតអំពីថ្ម------------------------------------------------------------------------------------------ ៣២៨
-វត្ថុផលិតអំពីដីដុត---------------------------------------------------------------------------------------- ៣៣១
៤.៥ សក្ខីកម្មរួម----------------------------------------------------------------------------------------------- ៣៣៦

## ជំពូកទី ៥
## ការប្រៀបធៀបស្ថានីយបន្ទាយគូនៃអរិយធម៌មេមត់ និងស្ថានីយផ្សេងទៀត

៥.១. លក្ខណៈស្ថានីយបន្ទាយគូ និងស្ថានីយភូមិមូលនៅតំបន់អង្គរ--------------------- ៣៣៧
៥.២. ស្ថានីយមានរាងមូលនៅប្រទេសថៃ-------------------------------------------------------- ៣៣៩
៥.៣. ស្ថានីយបឹងជើងឯក------------------------------------------------------------------------ ៣៤១
៥.៤. លក្ខណៈរបកគំហើញស្ថានីយបន្ទាយគូធៀបនឹងស្ថានីយសំរោងសែន----------- ៣៤៤
៥.៥. លក្ខណៈរបកគំហើញស្ថានីយបន្ទាយគូធៀបនឹងស្ថានីយម្លូព្រៃ-------------------- ៣៤៥
៥.៦. ជាតិពន្ធុនៅក្នុងតំបន់-------------------------------------------------------------------- ៣៤៦
៥.៧. កាលបរិច្ឆេទនៃស្ថានីយ------------------------------------------------------------------ ៣៤៨

## សេចក្តីសន្និដ្ឋាន

សេចក្តីសន្និដ្ឋាន----------------------------------------------------------------------------------- ៣៥៤
គន្ថនិទ្ទេស------------------------------------------------------------------------------------------- ៣៦៤

# សេចក្ដីសង្ខេប

ស្ថានីយបន្ទាយគូជាអ្វី?

«បន្ទាយគូ» ពាក្យនេះត្រូវបានអ្នកស្រុកនៅតំបន់ដីក្រហម ភាគខាងកើតទន្លេមេគង្គ បានស្គាល់ និងនិទានតៗគ្នារៀងរហូតមក។ អ្នកខ្លះហៅថា «បន្ទាយគូ» ខ្លះទៀតហៅថា «គូ ឬបន្ទាយបរមបុរាណ»។ «បន្ទាយគូ-គូ ឬបន្ទាយបុរមបុរាណ» នេះត្រូវបានធ្វើការស្រាវជ្រាវជាលើកទីមួយ ដោយក្រុមហ៊ុនចម្ការកៅស៊ូបារាំងក្នុងសម័យអាណានិគម នៅពេលឈូសឆាយដីដើម្បីដាំដុះកៅស៊ូ។ បន្ទាយគូជាសំណង់ដីរាងមូល មានកំពែងព័ទ្ធជុំវិញ មានគូរាងរង្វង់ខាងក្នុងបន្ទាប់ពីកំពែង មានច្រកចេញចូល និងមានបរិវេណខាងក្នុងជាកន្លែងរស់នៅ ( PEFEO, XXX, 1930)។

នៅពេលនោះហើយ ដែលអ្នកស្រាវជ្រាវបារាំង បានឱ្យឈ្មោះទីកន្លែងនោះថា « Village rond »។ អ្នកស្រាវជ្រាវ អ្នកនិពន្ធ និងអ្នកអានខ្មែរមួយចំនួនមិនបានសិក្សា និងឃើញស្ថានីយទាំងនោះផ្ទាល់ ក៏បានបកប្រែបន្តពីពាក្យបារាំងថា «ភូមិមូល» ទៅវិញ។ ក្នុងអត្ថបទរបស់លោក ត្រឹង ងា ចុះផ្សាយក្នុងសៀវភៅប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ១៩៧៣ អំពីស្ថានីយព្រែកឆ្លូង លោកមិនបានសិក្សា និងមិនបានឃើញទីតាំងស្ថានីយទាំងនោះដោយផ្ទាល់ឡើយ លោកគ្រាន់តែសិក្សាតាមរយៈរបាយការណ៍កំណាយបុរាណវិទ្យារបស់លោក ហ្វ្រូស លីយេ ក្នុងឆ្នាំ១៩៦២។ ក៏ប៉ុន្តែនេះគ្រាន់តែជាកំណត់ហេតុមួយ ដែលបានអះអាងអំពី ស្ថានីយព្រែកឆ្លូង។ តាមពិតព្រែកឆ្លូងគ្រាន់តែជាតំបន់ខ្ពង់រាប ដែលមានប្រភពទឹកជាច្រើនហូរនាំទៅចាក់ព្រែកឆ្លូងក្នុងស្រុកឆ្លូងខេត្តក្រចេះ ហើយនាំទឹកឆ្ពោះបន្តទៅទន្លេមេគង្គ។ វាមិនមែនជាឈ្មោះស្ថានីយនោះទេ។ តាមការស្រាវជ្រាវរបស់អ្នកនិពន្ធ ស្ថានីយព្រែកឆ្លូងនោះ គឺជាស្ថានីយបន្ទាយគូ ដែលអ្នកស្រុកក្នុងតំបន់ដីក្រហមខាងកើតទន្លេមេគង្គ បានឱ្យឈ្មោះ។ ចំណែកនៅភាគខាងត្បូងនៃប្រទេសវៀតណាម ក្នុងតំបន់ដីក្រហមនោះដែរ គេបានហៅ ស្ថានីយទាំងនេះថា «ហ៊ានចង» (មានន័យថាបន្ទាយមានមនុស្សរស់នៅ)។

ស្ថានីយបុរាណវិទ្យាទាំងនេះ ត្រូវបានកត់សម្គាល់ដោយមានសំណល់បុរាណវិទ្យា ដូចជា បំណែកកុលាលភាជន៍ ឧបករណ៍ប្រើប្រាស់ធ្វើអំពីថ្មមានដូចជា ពូថៅ និងថ្មសំលៀង ជាច្រើននៅរាយប៉ាយនៅលើផ្ទៃស្ថានីយ និងកប់ក្នុងដី រហូតដល់បច្ចុប្បន្ន។

តាមការសិក្សាស្រាវជ្រាវដំបូងៗបានឱ្យដឹងថា ស្ថានីយបន្ទាយគូ ដែលស្ថិតនៅតំបន់ខ្ពង់រាបដីក្រហម ភាគខាងកើតនៃប្រទេសកម្ពុជា និងភាគខាងត្បូងនៃប្រទេសវៀតណាម មានកាលបរិច្ឆេទក្នុងយុគថ្មរំលីង។ ការអះអាងនេះសម្អាងលើវត្ថុសិល្បៈ ដែលបានធ្វើកំណាយ និងសិក្សាវិភាគ ដោយលោក ដេហ្គា ក្នុងឆ្នាំ ១៩៩៩ ដោយលោក ហ្គ្រូសលីយេ ក្នុងឆ្នាំ ១៩៦៦ ដោយលោក កូចូ និង លោក ផេង ស៊ីថា ក្នុងឆ្នាំ១៩៩៧ ព្រមទាំងដោយលោក ម៉ាល់ឡឺរ៉េ ក្នុងឆ្នាំ ១៩៥៩ (Dega 1999, Groslier 1966, Kojo and Pheng 1997, Malleret 1959)។ ព័ត៌មានទាំងនេះបញ្ជាក់ឱ្យដឹងថា ការកំណត់កាលបរិច្ឆេទខាងលើមិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ នៅក្នុងការសន្និដ្ឋានថា ស្ថានីយទាំងនេះមានដំណើរពីទិសខាងកើតទៅខាងលិចនោះ ប៉ុន្តែការធ្វើកាលបរិច្ឆេទទាំងនោះ បានផ្តល់នូវទិន្នន័យមួយសម្រាប់ធ្វើជាទុននៅក្នុងការស្រាវជ្រាវនេះ។

ការបង្ហាញក្នុងអត្ថបទស្រាវជ្រាវនេះ គឺផ្តោតទៅលើស្ថានីយបន្ទាយគូ នៅក្នុងតំបន់ដីក្រហមភាគខាងកើតនៃទន្លេមេគង្គ ក្នុងខេត្តកំពង់ចាម ខេត្តក្រចេះ នៃប្រទេសកម្ពុជា និងខេត្តប៊ៀន ភឿក (Binh Phuoc) ក្នុងទំហំ ២០០ X ១៥០ គ.ម.។ រហូតដល់បច្ចុប្បន្ននេះ អ្នកនិពន្ធបានចុះបញ្ជី ស្ថានីយបន្ទាយគូទាំងនោះមានចំនួនរហូតទៅដល់៦២ស្ថានីយ។ ស្ថានីយទាំងនេះ មានទីតាំងស្ថិតនៅក្នុងរយៈកម្ពស់ពី ៦៥ ម. ទៅ ១៨៥ ម. ខ្ពស់ជាងកម្រិតកម្ពស់ផ្ទៃទឹកសមុទ្រ។ តាមរយៈសណ្ឋានដីខ្ពង់រាប ដែលជាជំរាលពីតំបន់ខ្ពង់រាបកម្រិតខ្ពស់ ពីខេត្តរតនៈគីរីឆ្លងកាត់ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ចុះមកខេត្តកំពង់ចាម ជាទូទៅស្ថានីយទាំងនោះតាំងនៅលើកំពូលខ្ពង់រាប។ ហើយជាករណីតែមួយដែលស្ថានីយបន្ទាយគូស្ថិតនៅចម្ងាយមួយ ដែលមានទំនាក់ទំនងជិតទៅនឹងប្រភពទឹក។

សរុបមកស្ថានីយបន្ទាយគូទាំងអស់ទាំងនៅកម្ពុជា និងវៀតណាម សុទ្ធតែត្រូវបានសង់តាមការគ្រោងទុកជាមុន គឺជានិច្ចជាកាលសង់ជាប់នឹងប្រភពទឹក។ ប្រភពទឹកនោះទៀតសោតជាប្រភពទឹក ដែលមានជាប្រចាំទាំងប្រាំងទាំងវស្សា។ ស្ទឹងជ្រៃមាំង ព្រែកឆ្លូងដែលហូរចុះមកទន្លេមេគង្គ ជាប្រភពយ៉ាងសំខាន់ សម្រាប់ការតាំងទីរបស់ស្ថានីយដោយសារប្រភពទឹក និងមច្ឆា ជាចំណែកមួយយ៉ាងសំខាន់សម្រាប់បុព្វការីជនដែលបានរស់នៅក្នុងស្ថានីយបន្ទាយគូទាំងនោះ។

ស្ថានីយបន្ទាយគូមានរាងជារង្វង់ដោយមាន កំពែងរាងមូល គូរាងមូលបន្ទាប់ពីកំពែង និងបរិវេណខាងក្នុងមូល ដែលមានអង្កត់ផ្ចិតប្រហែល ២៥០ ម អង្កត់ទទឹងកំពែងប្រហែល ២០ ម អង្កត់ទទឹងគូ ប្រហែល ២៥ ម និងអង្កត់ទទឹងបរិវេណកន្លែងរស់នៅ នៃផ្ទៃ

ខាងក្នុងប្រហែល ២០៥ ម។ ដូច្នេះទំហំមាឌរបស់គូមាន ២៨ ៦៤៩ ម³ ក្រឡាផ្ទៃទាំងមូលនៃស្ថានីយមានប្រហែល ៨៩ ០៦២,៥ ម² កំលាំងធ្វើការ ដើម្បីសាងសង់ស្ថានីយមួយយ៉ាងតិចមានពី ១៥០នាក់ ទៅ២០០នាក់ ហើយយ៉ាងតិចបំផុត ក៏ចំណាយពេលបួនទៅប្រាំខែដែរ (មើលចំណុច ២.៤.៨ របៀបនៃការសាង សង់ស្ថានីយ)។ ក្នុងតំបន់ត្រូពិចក្តៅហើយសើម សម្បូរភ្លៀង ការសាងសង់ស្ថានីយ មួយអាច ប្រព្រឹត្តទៅបានតែក្នុងខែប្រាំង។ ការសិក្សាបានបញ្ជាក់ថា ដីយកចេញពីបាតគូ ដើម្បីសង់កំពែង ប្រហែល ៨៨,១២៥% និងដីយកចេញពីគូ ដើម្បីសង់កន្លែងរស់នៅប្រហែល១១,៧៥%។ ជាទូទៅស្ថានីយបន្ទាយគូ ទាំងនោះមានច្រកចេញចូលពីរ។ តាមរយៈការសិក្សានេះដែរបង្ហាញថា ការសាងសង់គូ មិនមែនសម្រាប់ផ្ទុកទឹកឡើយ។ បាតគូនេះទំនងអាចជាកន្លែងក្រោលសត្វ ឬជាកន្លែង ផ្សាំងសត្វពាហនៈ។

ការសិក្សាបុរាណវិទ្យា ដោយប្រើបច្ចេកទេសកំណាយបានបង្ហាញថា មានការស្នាក់នៅ ឬតាំងទីជាច្រើនឆ្នាំ តាមរយៈរបកគំហើញស្រទាប់បុរាណវិទ្យានៅក្នុងស្ថានីយបន្ទាយគូ១៥ ដែលបាន ធ្វើកំណាយកន្លងមក។ ស្រទាប់បុរាណវិទ្យា ដែលមានកម្រាស់ប្រមាណជុំវិញមួយម៉ែត្រ បន្សល់នូវ ភស្តុតាង វត្ថុសិល្បៈជាច្រើន គួសបញ្ជាក់ថា ស្ថានីយទាំងនោះមានស្លាកស្នាមមនុស្សរស់នៅយូរ។

ការតាំងទីនៅមួយកន្លែង បង្ហាញអំពីសង្គមមួយច្បាស់លាស់។ ការសិក្សាអំពីស្ថានីយបន្ទាយគូទាំងនោះ ក៏បានបង្ហាញឱ្យដឹងអំពីការរស់នៅ និងប្រព័ន្ធគ្រប់គ្រងមួយដ៏ចាំបាច់ដែលត្រូវការ មេដឹកនាំត្រឹមត្រូវក្នុងការចាត់ចែង កសាងស្ថានីយនីមួយៗដែរ។ ប្រសិនបើមើលស្ថានីយឡុកតាន់២ (Loc Tan 2) មានទំហំ ១០ហិកតា និងស្ថានីយត្របែកដែលមានទំហំជាង១៥ហិកតាវិញ យើងឃើញថា រយៈពេលនៃការសាងសង់ស្ថានីយនីមួយៗ ត្រូវការពេលវេលាយ៉ាងច្រើន (សូមមើលជំពូកទី២ របៀបនៃការសាងសង់ស្ថានីយ)។ ការដឹកនាំស្ថាបនាកំពែងគូ និងបរិវេណខាងក្នុងស្ថានីយទាំងអស់នេះប្រាកដជាមានមេក្រុម ឬមេកុល សម្ព័ន្ធដឹកនាំ ទើបអាចសម្រេចបាន។

ការសិក្សាពីបន្ទាយគូ ក៏បានឱ្យយើងដឹងបន្ថែមទៀត អំពីលក្ខណៈសង្គមនៃអ្នកធ្វើកសិកម្ម តឹកតាងនៃការដាំស្រូវ ត្រូវបានឃើញយ៉ាងច្បាស់នៅលើបំណែកកុលលាភាជន៍។ ស្ថានីយបន្ទាយគូ គឺជាសក្ខីភាពនៃសង្គមមួយ ដែលមានការរីកចម្រើន និងមានរចនាសម្ព័ន្ធ ដឹកនាំត្រឹមត្រូវ ហើយមានរបាយប្រជាជនច្រើន មានឋានៈក្នុងសង្គមដែលបញ្ជាក់តាម ប្រព័ន្ធកសាងស្ថានីយនោះតែម្តង ដោយស្តែងលើវិសាលភាពនៃការសាងសង់ស្ថានីយធំៗទាំងនោះ។ (លោក ហ្វ្រាង រ៉ូបឺត ឆ្នាំ១៩៧៥ បានបញ្ជាក់ថា

សហគមន៍វប្បធម៌ និងកសិកម្ម ជាទូទៅមានការរស់នៅមួយកន្លែង របាយប្រជាជន ច្រើន និងមានអ្នកដឹកនាំ) *(Agricultural Cultural communities are generally permanent, with high population densities and leadership, Frank Robert, 1975)*។ ប្រសិនបើពុំមានអ្នកដឹកនាំដែលជាមេកន្ទ្រាញនោះទេ ស្ថានីយបន្ទាយគូ មិនអាចកសាងបានរហូតដល់រាប់សិបនោះដែរ។ អ្នកនិពន្ធលើកសក្ខីកម្មខាងលើមកបង្ហាញ ដើម្បីគូសបញ្ជាក់នូវសម្មតិកម្មខាងដើមថា ស្ថានីយ បន្ទាយគូ គឺជាសណ្ឋាននៃការរៀបចំសង្គមតំបូងៗ ដែលបានចាប់កំណើតនៅតំបន់ឥណ្ឌូចិន ជាពិសេសនៅកម្ពុជា។

ចំពោះកាលបរិច្ឆេទតាមវិទ្យាសាស្ត្រ នៃស្ថានីយបន្ទាយគូវិញយើងឃើញថា មិនទាន់មានភាពជាក់លាក់នៅឡើយទេ។ មានទិន្នន័យតិចតួចបំផុត ទាក់ទងនឹងការកំណត់កាលបរិច្ឆេទ នៃស្ថានីយបន្ទាយគូទាំងនេះ ដូចជានៅក្នុងស្ថានីយបន្ទាយគូ ភូមិក្រមេង មានអាយុចាប់ពី ២២៩០ឆ្នាំ មុនគ្រិស្តសករាជ ដល់២០៣០ឆ្នាំ មុនគ្រិស្តសករាជ ក្នុងជម្រៅស្រទាប់ វប្បធម៌ពី ៩០ស.ម-១០០ ស.ម.។ ចន្លោះអាយុកាលនេះ អាចបញ្ជាក់ថា ស្ថានីយបន្ទាយគូ ភូមិក្រមេង ស្ថិតនៅចន្លោះ យុគថ្មរំលីង និងយុគលោហៈ។

ដើម្បីស្ថិរភាព និងការរីកចម្រើនរបស់ខ្លួនមនុស្សសម័យមុនបានសាងទីជម្រកបន្ទាយគូ នេះឡើងសម្រាប់ងាយស្រួលក្នុងការការពារខ្លួន ងាយស្រួលដល់ការប្រាស្រ័យទាក់ទងគ្នាក្នុងកុលសម្ព័ន្ធ ក៏ដូចជារៀបចំការបរបាញ់ បេះផ្លែឈើ និងធ្វើកសិកម្មជាដើម។ ដោយហេតុនេះហើយ ស្ថានីយបន្ទាយគូភាគច្រើន ត្រូវបានកសាងឡើងមានលក្ខណៈប្រមូលផ្តុំជាក្រុម ដែលនៅក្នុងក្រុមនីមួយៗ មានទីតាំងស្ថិតនៅមិនឆ្ងាយប៉ុន្មានពីគ្នា។ ទាំងនេះឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់ថា នៅសម័យមុនមនុស្ស ដែលរស់នៅក្នុងស្ថានីយទាំងនោះចេះសាមគ្គីគ្នាជួយការពារគ្នាក្នុងសង្គម។

សង្គមកសិកម្មនៅស្ថានីយបន្ទាយគូនេះ មានសមត្ថភាពខ្ពស់ក្នុងការធ្វើហត្ថកម្ម។ យើងឃើញស្លាកស្នាមគ្រាប់ស្រូវ ដែលមនុស្សនៅក្នុងអរិយធម៌នេះ បានបន្សល់ក្នុងការលាយដីឥដ្ឋ និងសារធាតុសរីរាង្គ ដើម្បីសូនកុលាលភាជន៍។ ក្រៅពីដំណាំស្រូវ មនុស្សរស់នៅក្នុងស្ថានីយទាំងនោះ ប្រហែលជាចិញ្ចឹមសត្វផងដែរ។ បាតគូ ទំនងជាកន្លែងចិញ្ចឹម ឬជាក្រោលគោ ក្របី ឬក៏ជ្រូក ព្រោះថា គូ មិនមែនជាប្រឡាយ សម្រាប់ផ្ទុកទឹកទេ។ ប្រភេទឧបករណ៍សម្រាប់ផលិតអំបោះហៅ «ខ្នារ» ក៏ត្រូវបាន រកឃើញនៅក្នុងស្ថានីយបន្ទាយគូដែរ ដែលសបញ្ជាក់ឱ្យឃើញថា សហគមន៍មនុស្ស នាពេលនោះចេះផលិតអំបោះ រួចជាស្រេចទៅហើយ។ តាមរយៈកំណាយបុរាណវិទ្យា មានកុលាលភាជន៍ជាច្រើន ដែលយើងបានជួបប្រទះ មានប្រភេទ និងទម្រង់ខុសៗពីគ្នា

ព្រមទាំងក្បាច់លម្អ ផ្សេងៗជាច្រើនទៀត។ កុលាលទាំងនោះជាឧបករណ៍ចាំបាច់សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃរបស់សហគមន៍នោះ។ ជំនីកពត្លាក់ ឬដឹងពត្លាក់ ដែលជាឧបករណ៍ប្រើប្រាស់ធ្វើអំពីថ្ម ត្រូវបានឃើញនៅរាយប៉ាយលើផ្ទៃស្ថានីយ គ្រប់ស្ថានីយបន្ទាយគូ ដែលយើងស្គាល់បានថា ជាប្រភេទពូថៅ ធ្វើអំពីថ្ម នៅសម័យនោះ។ ពូថៅថ្មធម្មតា ពូថៅថ្ម មានស្មា ថ្មសំលៀង និងផ្លែដឹង បានបង្ហាញថា ជាបុព្វការីជនដែលមានភាពប៉ិនប្រសព្វ នៅក្នុងការផលិតឧបករណ៍ ប្រើប្រាស់ទាំងនោះ គឺជាអ្នកមានរបរកសិកម្ម។ ក្រៅពីនេះប្រភពទឹក ដែលមានព្រែកឆ្លូង ទន្លេចាំ (ទន្លេជុងណាយ) ដែលហូរចាក់ ទៅទន្លេសៃហ្គុន ប្រហែលជាប្រភពយ៉ាងសំខាន់មួយទៀត សម្រាប់គមនាគមន៍។ ការរកឃើញផ្លែពន្លាក ធ្វើឱ្យយើងអាចកាត់យល់បានថា ប្រហែលវាជាឧបករណ៍មួយសំខាន់ប្រើសម្រាប់កាប់ ឬចាំងឈើ ធ្វើទូក។ ការប្រើផេះ ឈើឈ្លីចដោយមិនមានអំបិល ជារឿងមួយសំខាន់របស់អ្នកស្រុកភ្នំ នៅតំបន់ខ្ពង់រាបខាងកើតទន្លេមេគង្គ ក៏ប៉ុន្តែផេះឈើឈ្លីចនេះមិនគ្រប់គ្រាន់ ហើយក៏មិនអាចជួយឱ្យក្រុមមនុស្សនាសម័យកាលនោះមានសុខភាពល្អទេ ព្រោះសារជាតិស៊ូត មាននៅក្នុងផេះនោះ ច្រើនធ្វើឱ្យខនិជអំបិលមានតិចបណ្ដាលឱ្យសាច់សត្វ ដែលពួកគេបរបាញ់បានងាយស្អុយរលួយ។ ជំនួញអំបិលប្រហែលជាមានរវាងអ្នកដែលរស់នៅឆ្ងាយពីសមុទ្រ និងអ្នកនៅជិតសមុទ្រ។ គេបានប្រទះ ឃើញកុលាលភាជន៍ ដែលគេប្រើសម្រាប់ផលិតអំបិលនៅតាមស្ថានីយមួយចំនួនក្បែរសមុទ្រ ប្រទេសវៀតណាម។ ឧបករណ៍ឧស្សាហកម្មមួយចំនួនត្រូវបានប្រទះឃើញក្នុងរណ្ដៅកំណាយក្នុង ស្ថានីយបន្ទាយគូ ដូចជា កងធ្វើអំពីកែវ និងអង្កាំ ជាដើម។ វត្ថុទាំងនោះត្រូវបានសន្និដ្ឋានថា ជាវត្ថុនាំចូលហើយមិនមែនផលិតនៅលើស្ថានីយបន្ទាយគូនោះទេ។ តាមរយៈការពិសោធន៍ទៅលើ កង ធ្វើអំពីកែវនាំឱ្យយើងសន្និដ្ឋានបានថា ទំនាក់ទំនងពាណិជកម្មប្រាកដជាមាន។ យោងតាម លោក គ្លូវើ និង លោក ហេន ឌែសុន (Glover and Henderson, 1995) បានបញ្ជាក់ឱ្យដឹងថា មាន តំបន់បីដែលគេចាត់ទុកជា មជ្ឈមណ្ឌលផលិតកែវមុនដំបូង ហើយបាននាំចូលមកក្នុង តំបន់អាស៊ីអាគ្នេយ៍ ទីមួយនៅប្រទេសឥណ្ឌាទីពីរនៅប្រទេសចិន និងទីបីនៅតំបន់មេឌីទែរ៉ាណេ។

តាមលទ្ធផលនៃការពិសោធន៍ ទៅលើកងធ្វើអំពីកែវ ដែលបានមកពីកំណាយស្ថានីយក្រែក ៥២/៦២ ឃើញថា មានសមាសធាតុស្រដៀងគ្នា ទៅនឹងបំណែកកងធ្វើអំពីកែវ ផលិតនៅប្រទេសឥណ្ឌា។ នេះជាសក្ខីកម្មមួយអាចសន្និដ្ឋានថា បុព្វការីជនដែលរស់នៅលើស្ថានីយបន្ទាយគូ មាន ទំនាក់ពាណិជ្ជកម្មជាមួយនឹងបរទេស។

ឧបករណ៍សិល្បៈ ដែលជាថ្មសម្លេងត្រូវបានរកឃើញជាច្រើននៅលើស្ថានីយបន្ទាយគូនៅឡុកនិញ និងនៅស្ថានីយហ្រ្គុសលីយេ។ ការផលិតថ្មសំឡេងនេះបញ្ជាក់ពីសង្គមដែលមានការរីកចម្រើន នៃអរិយធម៌មេមត់នេះ។

ជារួមការស្រាវនៅលើតំបន់ដីក្រហមនេះ មិនបានជួបប្រទះលោហធាតុអ្វីឡើយ ដោយសារអាស៊ីតរបស់ដី ក៏ប៉ុន្តែលទ្ធផលទាំងនេះ ជាសក្ខីកម្មមួយយ៉ាងច្បាស់ គូសបញ្ជាក់ថា ស្ថានីយបន្ទាយ គូនៃអរិយធម៌មេមត់ ជាអរិយធម៌មួយយ៉ាងសំខាន់នៅអាស៊ីអាគ្នេយ៍នេះ ហើយជាមោទនភាពចំពោះ ប្រទេសកម្ពុជាយើង ដែលមានអរិយធម៌ដ៏ចំណាស់របស់ខ្លួនជាស្រេចមុននឹងឈានចូល សម័យហ្វូណន សម័យចេនឡា និងសម័យអង្គរ ជារៀងតៗមក។

ជាចំពោះមុខ ដើម្បីឱ្យយល់កាន់តែស៊ីជម្រៅលើអរិយធម៌មេមត់នេះ គឺត្រូវធ្វើការស្រាវជ្រាវជាបន្តទៅទៀត ដោយការធ្វើកំណាយ ហើយក៏ត្រូវធ្វើកាលបរិច្ឆេទដែលមានលក្ខណៈ វិទ្យាសាស្ត្រទំនើប តាមរយៈកាបូន-១៤ ឱ្យបានលើគ្រប់ស្ថានីយទាំងអស់ និងហ្មត់ចត់គ្រប់ស្រទាប់បុរាណវិទ្យា ទាំងអស់។